# របាយការណ៍
# លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំខែមករា ឆ្នាំ២០១៦

ក្នុងរយៈពេលមួយខែកន្លងមកនេះ ទាំងថ្នាក់ដឹកនាំ និងគ្រប់អង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត ចំណុះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានខិតខំប្រឹងប្រែងធ្វើការងារយ៉ាងមោះមុតជាប្រចាំ គឺធ្វើយ៉ាងណាឲ្យសម្រេចបានជាដំណាក់កាលៗតាមផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ ដែលក្រសួងបានរៀបចំឡើង ដោយដើរតាមគន្លងនៃគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ ដោយអនុលោមយ៉ាងខ្ជាប់ខ្ជួនតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤ -២០១៨ ក្នុងវិស័យវប្បធម៌ និងស្របតាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។ លទ្ធផលដែលក្រសួងសម្រេចបានដូចមានជម្រាបជូនខាងក្រោម ៖

## ១. សកម្មភាព និងលទ្ធផលការងារ ៖

### ១.១. សកម្មភាពថ្នាក់ដឹកនាំ ៖

*<u>សកម្មភាពក្នុងប្រទេស ៖</u>*

- **<u>ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ៖</u>** លោកជំទាវរដ្ឋមន្ត្រី ចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី "របៀបចងក្បិន និងស្លៀកសម្លុយក្នុងពិធីអាពាហ៍ពិពាហ៍តាមបែបប្រពៃណីខ្មែរ វគ្គ២" នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ។
- **<u>ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ៖</u>** លោកជំទាវរដ្ឋមន្ត្រី ចូលរួមជាអធិបតីក្នុងពិធីសម្ពោធបើកពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពី "ហូលពិតានខ្មែរ" នៅសារមន្ទីរជាតិ។
- **<u>ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ៖</u>** លោកជំទាវរដ្ឋមន្ត្រី ចូលរួមក្នុង ពិធីប្រគល់រង្វាន់មរតកវប្បធម៌ខ្មែរ ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ជំនាន់ទី៧ ឆ្នាំ២០១៦ នៅសាលមហោស្រពកោះពេជ្រ។
- **<u>ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ៖</u>** លោកជំទាវរដ្ឋមន្ត្រី អនុញ្ញាតជូនក្រុមការងារអង្គការ FOKCI's ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង។
- **<u>ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ៖</u>** លោកជំទាវរដ្ឋមន្ត្រី ចូលរួមក្នុងកម្មវិធីប្រគល់មេដាយកិត្តិយស និងជប់លៀងដែលរៀបចំដោយ អង្គការ FOKCI's នៅសារមន្ទីរជាតិ។

- <u>**ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ៖**</u> លោកជំទាវរដ្ឋមន្ត្រី ចូលរួមក្នុងពិធី**តភ្ជាប់ព្រះសិរ្សជាមួយដងខ្លួនព្រះហរិហរៈ** និងពិធីប្រគល់ជាផ្លូវការនូវវិញ្ញាបនប័ត្រទទួលស្គាល់ "**ល្បែងទាញព្រ័ត្រ**" ចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ នៃអង្គការយូណេស្កូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** នៅសារមន្ទីរជាតិ។

## ១.២ . ការរៀបចំព្រឹត្តិការណ៍សំខាន់ៗ ៖

- កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នាទីស្តីការក្រសួងមានរៀបចំបើកសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ ក្រោមអធិបតីភាពលោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នាសាលសន្និសីទចតុម្មុខ ក្រសួងបានរៀបចំពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រ សិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ដែលជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមជាកិត្តិយសពីថ្នាក់ដឹកនាំជាន់ខ្ពស់បណ្តាក្រសួង-ស្ថាប័ន ភ្ញៀវជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំ-មន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សិល្បករ-សិល្បការិនីសរុប ចំនួន៧០០នាក់។
- កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ នាសារមន្ទីរជាតិភ្នំពេញ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំ**ពិធីតភ្ជាប់ព្រះសិរ្សជាមួយដងខ្លួនព្រះហរិហរៈ**និងពិធីប្រគល់ជាផ្លូវការនូវវិញ្ញាបនប័ត្រទទួលស្គាល់ "**ល្បែងទាញព្រ័ត្រ**" ចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ នៃអង្គការយូណេស្កូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

## ១.៣. សកម្មភាព និងលទ្ធផលការងារតាមអង្គភាព ៖

### *១.៣.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ៖*

<u>*នាយកដ្ឋានរដ្ឋបាលទូទៅ៖*</u>

- បានទទួលលិខិតចូលពីគ្រប់ស្ថាប័នចំនួន២២៩ច្បាប់ និងបញ្ជូនលិខិតចេញទៅគ្រប់ស្ថាប័នចំនួន២៣៥ច្បាប់។ ទន្ទឹមនេះក៏បានតាក់តែងលិខិតរដ្ឋបាល និងលិខិតផ្សេងៗទៀតបានចំនួន២៨ច្បាប់ តាមបញ្ជារបស់ថ្នាក់ដឹកនាំ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលដោយបានរៀបចំ កម្លាំងសន្តិសុខ និងនគរបាលយាមកាមប្រចាំការពេលថ្ងៃ និងយប់បានល្អប្រសើរក្នុងការថែរក្សាសុវត្ថិភាពនៅទីស្តីការក្រសួង។

- បានធ្វើការបែងចែកសៀវភៅរាជកិច្ចជូនថ្នាក់ដឹកនាំតាមគោលការណ៍ប្រចាំខែ។
- ការិយាល័យព័ត៌មានវិទ្យាបានបន្តដំណើរការជាធម្មតាតាមផែនការកំណត់។

***<u>នាយកដ្ឋានបុគ្គលិក ៖</u>***

- បានបញ្ចូលប្រាក់បំណាច់មុខងារមន្ត្រីសិក្សាក្រៅប្រទេសចំនួន ០១នាក់ និងមន្ត្រីតែងតាំងថ្មីចំនួន ២២នាក់ ក្នុងតារាងទូទាត់បៀវត្ស។
- បានប្រកាសជូនមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សឱ្យចូលបម្រើការងារវិញចំនួន៧នាក់។

***<u>នាយកដ្ឋាននីតិកម្ម ៖</u>***

- បានចូលរួមប្រជុំសេចក្តីសម្រេចរួមលើផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់ក្រសួង នៅបន្ទប់លេខាធិការដ្ឋាន គ.ជ.អ.ប.។
- បានចូលរួមប្រជុំលើកទី១១ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្រសួងមហាផ្ទៃ។
- បានចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការជក់បារី និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ នៅក្រសួងសុខាភិបាល។

***<u>នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ៖</u>***

- បានបានធ្វើសំណុំលិខិតស្នើសុំថវិការដ្ឋសម្រាប់ប្រាក់បំណាច់ និងប្រាក់បៀវត្សមន្ត្រីរាជការ និងសម្រាប់ឧបត្ថម្ភជីវភាពមរតកមនុស្សរស់១៦នាក់ ប្រចាំខែមករា ឆ្នាំ២០១៦។
- បានធ្វើរបាយការណ៍ និងសាលាកប័ត្របង្វែរចំណូល ៖
    - លក់សំបុត្រចូលទស្សនាសារមន្ទីរជាតិខែធ្នូ ឆ្នាំ២០១៥។
    - ត្រួតពិនិត្យវិស័យភាពយន្តខែធ្នូ ឆ្នាំ២០១៥។
    - ត្រួតពិនិត្យការនាំចេញ នាំចូលវត្ថុសិល្បៈខែធ្នូ ឆ្នាំ២០១៥។
- បានធ្វើរបាយការណ៍ និងសាលាកប័ត្របង់ចំណូល៖
    - ជួលមណ្ឌលរូបភាព (អាឡឺយ៉ង់) ខែធ្នូ ឆ្នាំ២០១៥។
    - ជួលទីតាំងមហោស្រពខេត្តកំពង់ចាម ឆ្នាំ២០១៥។
- បានធ្វើសំណើសុំគោលការណ៍ចំណាយ ៖
    - រៀបចំសន្និបាតបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦។
    - រៀបចំទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៨ ឆ្នាំ២០១៦។
    - រៀបចំមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំ២០១៦។
- បានធ្វើលិខិតស្នើសុំអាណត្តិចំណាយទូទាត់៖
    - ថ្លៃប្រើប្រាស់សេវាទូរស័ព្ទលើគុខែធ្នូ ឆ្នាំ២០១៥។
    - ថ្លៃប្រើប្រាស់សេវាប្រមូល និងដឹកជញ្ជូនសម្រាមខែមករា ឆ្នាំ២០១៦។
- បានធ្វើអាណត្តិចំណាយទូទាត់ថ្លៃទូទាត់បេសកកម្មតាមបណ្តារាជធានី-ខេត្ត ឆ្នាំ២០១៥។
- ចាប់ផ្តើមធ្វើឯកសាររដ្ឋទេយ្យជុំទី១ ឆ្នាំ២០១៦។

***នាយកដ្ឋានសម្ភារៈ និងបរិក្ខារ ៖***

- បានធ្វើលិខិតបង្គាប់ការស្ដីពីការបង្កើតគណៈកម្មការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៥។
- បានធ្វើសំណើសុំធ្វើស្លាកលេខម៉ូតូរដ្ឋជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្ដាល កំពង់ធំ និងព្រៃវែង។
- បានបន្តធ្វើការផ្គត់ផ្គង់សម្ភារៈការិយាល័យ និងជួសជុលសម្ភារៈការិយាល័យជូនគ្រប់បណ្ដាអង្គភាព និងថ្នាក់ដឹកនាំ។
- បានលើកគម្រោង ៖
    - ទិញសម្ភារៈការិយាល័យឆមាសទី១ ឆ្នាំ២០១៦។
    - ទិញប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦។
    - ទិញគ្រឿងសង្ហារិមឆ្នាំ២០១៦។
    - ទិញសម្ភារៈបច្ចេកទេសឆ្នាំ២០១៦។
    - ទិញឯកសណ្ឋានសន្តិសុខ និងឆ្នាំប្រាសាទឆ្នាំ២០១៦។
    - ផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍រថយន្តឆ្នាំ២០១៦។
    - ជួសជុលម៉ាស៊ីនត្រជាក់គ្រប់បណ្ដាអង្គភាព និងតបណ្ដាញអគ្គិសនីទីស្ដីការក្រសួង និងតខ្សែមេថ្មី។
    - ជួសជុលកែលម្អបន្ទប់អនាម័យ និងប្រព័ន្ធលូសាលាមធ្យមវិចិត្រសិល្បៈ។

***ការងារអង្គភាពលទ្ធកម្ម***

- បានធ្វើសំណើសុំគោលការណ៍ស្ដីពីការងារ ៖
    - ផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦។
    - ផ្គត់ផ្គង់សម្ភារៈការិយាល័យ និងការបោះពុម្ពឆមាសទី១ ឆ្នាំ២០១៦។
    - ផ្គត់ផ្គង់គ្រឿងសង្ហារិមប្រចាំឆ្នាំ២០១៦។
    - ផ្គត់ផ្គង់សម្ភារៈបច្ចេកទេសប្រចាំឆ្នាំ២០១៦។
    - ថែទាំ និងជួសជុលម៉ាស៊ីនត្រជាក់គ្រប់បណ្ដាអង្គភាព និងតបណ្ដាញអគ្គិសនីក្នុងទីស្ដីការក្រសួង និងបណ្ដាញខ្សែមេថ្មីឆ្នាំ២០១៦។
    - ផ្គត់ផ្គង់សម្ភារៈសម្រាប់ថែទាំសម្ភារៈឧបករណ៍រថយន្តឆ្នាំ២០១៦។
    - ផ្គត់ផ្គង់ឯកសណ្ឋានឆ្នាំប្រាសាទប្រចាំឆ្នាំ២០១៦។

***នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ៖***

- បានរៀបចំឯកសារសម្រាប់សន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦។
- បានរៀបចំធ្វើរបាយការណ៍តាមរបបកំណត់ប្រចាំខែមករា និងបានផ្ញើគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទៅតាមកាលកំណត់របស់រាជរដ្ឋាភិបាល។
- បានបន្តរៀបចំតារាងតាមដានការអនុវត្តផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំត្រីមាសទី១ ដើម្បីធានាប្រសិទ្ធិភាពក្នុងការអនុវត្តផែនការឆ្នាំ២០១៦។
- បានបន្តរៀបចំផែនការឆ្នាំ២០១៦-២០១៨។

- បានបន្តរៀបចំប្រមូលទិន្នន័យស្ថិតិវប្បធម៌។

***<u>នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ៖</u>***

- បានចូលរួមពិភាក្សាការងារក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងអនុក្រុមការងារវិធានដើមកំណើតនៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានចូលរួមប្រជុំកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគ និងពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម។
- បានចុះបញ្ជីការពារស្នាដៃអក្សរសាស្ត្រចំនួន០៦ស្នាដៃ និងការបោះពុម្ពសៀវភៅចំនួន០៣ស្នាដៃ។
- បានទទួលថវិកាចំនួន៣០០.០០០រៀល បង់ចូលថវិការដ្ឋ។

***<u>នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ៖</u>***

- បានសម្រួលបែបបទជូនថ្នាក់ដឹកនាំ មន្ត្រីជំនាញទៅចូលរួមប្រជុំ បំពេញបេសកកម្ម និងសម្តែងសិល្បៈបានចំនួន០៤លើក៖ នៅប្រទេសថៃ ជប៉ុន និងណាមីប៊ី។

## ១.៣.២. អគ្គនាយកដ្ឋានបេតិកភណ្ឌ ៖

***<u>នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ៖</u>***

**<u>ក.ការងារអភិរក្សដ្ឋានអង្គរ ៖</u>**

- បានចូលរួមត្រួតពិនិត្យវត្ថុសិល្បៈចំនួន៣៦ប្រភេទ ដែលសាលាប៉ាឡឺម៉ូទើបនឹងយកមកពីវត្តរាជបូព៌ ដើម្បីសម្អាត និងជួសជុល។
- បានស្កេនបញ្ជីសារពើភណ្ឌវត្ថុសិល្បៈសម័យបារាំងចាប់ពីលេខ១២០២ ដល់១២៩៧។

**<u>ខ.ការងារស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិសាស្ត្រក្នុងកិច្ចការពារតំបន់ប្រាសាទ៖</u>**

- បានស្កេនកាតាឡុករូបថតចាស់ៗចំនួន១៤៩សន្លឹក ទុកជាឯកសារ។
- បានជួបជាមួយអ្នកជំនាញកុំព្យូទ័រពិភាក្សាអំពីការបង្កើត Software ដើម្បីរៀបចំគ្រប់គ្រងទិន្នន័យសម្រាប់មជ្ឈមណ្ឌលឯកសារបន្ទាយឆ្មារ។

**<u>គ.ការងារជួសជុលប្រាសាទ និងសំណង់បុរាណ ៖</u>**

- បានចុះទៅវាស់វែង និងពិនិត្យទីតាំងដែលត្រូវធ្វើការជួសជុលទល់ទ្រប្រាសាទបន្ទាយទ័ព ខេត្តបន្ទាយមានជ័យ និងស្ពានទិព្វ ខេត្តឧត្តរមានជ័យ។

**<u>ឃ.ការងារគ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ ៖</u>**

- បានចុះទៅអង្កេតការខូចខាត និងធ្វើការសម្អាតសាកល្បងសសរបិទមាសនៅវត្តមហាលាភ និងវត្តសំរោង ខេត្តកំពង់ចាម។
- សហការជាមួយការិយាល័យអភិរក្សអង្គរសិក្សាអំពីផ្តែរកំណត់តាមអាយុកាល។
- ថតចម្លងរូបថតចាស់ពីបណ្ណាល័យ EFEO : Khmer temple of Angkor បានចំនួន០២ឌីស។

**<u>ង.ការងារអភិរក្សតាមបណ្តាខេត្ត៖</u>**

*អភិរក្សដ្ឋានកំពង់ធំ និង ព្រះវិហារ ៖*

- បន្តចូលរួមសហការជាមួយអង្គការ Waseda ចងក្រងឯកសារ និងជួសជុលប្រាសាទសំបូរព្រៃគុក នៅខេត្តកំពង់ធំ ។

*អភិរក្សដ្ឋានបាត់ដំបង បន្ទាយមានជ័យ និង ឧត្តរមានជ័យ ៖*

- បានកាត់ដើមស្តង់ដែលដុះរំលើងជញ្ជាំងថ្មបាយក្រៀម កំពែងទី២ មុខខាងជើង ផ្នែកខាងលិចនៃប្រាសាទបន្ទាយឆ្មារ។
- បានចាក់ថ្នាំសម្លាប់កូនឈើតូចៗដែលដុះឫសញែកថ្មជញ្ជាំងប្រាសាទចំនួន១២កន្លែង។

**<u>ច.ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ៖</u>**

- កិច្ចសហការជាមួយអង្គការ G.H.F និង SOAS, University of London ក្នុងការអភិរក្ស និងជួសជុលប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ៖
    - o បានកំពុងរៀបចំផែនការអភិរក្សរយៈពេល៥ឆ្នាំ ប្រាសាទតាណៃម រាល់ចំណុចហានិភ័យ និងរោងទងមុខខាងជើង ផ្នែកខាងកើត របស់ប្រាសាទបន្ទាយឆ្មារ។
- កិច្ចសហការជាមួយអង្គការ Waseda ជួសជុលប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ ៖ បាននិងកំពុងបន្តការងារជួសជុលប្រាសាទ N1 ។

## <u>*នាយកដ្ឋានសារមន្ទីរ ៖*</u>

**<u>ក.សារមន្ទីរជាតិភ្នំពេញ៖</u>**

- បានទទួលបំណែកបដិមាមកពីប្រាសាទចិន និងបំណែកជើងទម្របដិមានាងឧមារាំចំនួន១២ដុំមកពីប្រាសាទក្រហម ក្រុមប្រាសាទកោះកេរ ពីសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។
- បាន Back-up ទិន្នន័យនៅក្នុងប្រព័ន្ធ Data base ។
- បានសហការជាមួយលោកស្រី **ចាន់ ស្រី** នាយិកាប្រចាំតំបន់ក្រុមសិក្សាស្រាវជ្រាវគម្រោងពិដានជប៉ុនអង្គការគាំពារកុមារខ្មែរ បានរៀបចំពិធីសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី "**ហ្វាលពិដានខ្មែរ**" នៅសារមន្ទីរជាតិ ក្រោមអធិបតីភាព **ឯកឧត្តម ជុច ភឿន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ឯកឧត្តម **YUJI Kumamaru** ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា។
- បានជួសជុលរូបចម្លាក់បាន**៣១រូប។**
- បានទទួលភ្ញៀវឲ្យចូលទស្សនាសារមន្ទីរជាតិភ្នំពេញមានគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ភ្ញៀវជាតិ-អន្តរជាតិ សិក្ខាកាម សិស្ស និស្សិត ព្រះសង្ឃ សរុបចំនួន **២៥.២១១នាក់** ក្នុងនោះមានភ្ញៀវជាតិចំនួន **២.៦៣០នាក់** ដែលទទួលបានចំណូលថវិកាចំនួន **៩២០.៥០០រៀល** បង់ចូលថវិការដ្ឋ និង ភ្ញៀវអន្តរជាតិចំនួន**១៤.០៤១នាក់** ដែល ទទួលបានចំណូលថវិកាចំនួន**៤៩.១៤៣ដុល្លា** បង់ចូលថវិការដ្ឋ និងភ្ញៀវចូលឥតបង់ថ្លៃចំនួន **៨.៥៤០នាក់។**

**<u>ខ.សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង៖</u>**

- ពិនិត្យនិងឆែកឯកសារ ដើម្បីរក្សាប៉ាល់ចំនួនពីរដងក្នុងមួយខែ។
- ស្កេនឯកសារចម្លើយសារភាពរបស់ជនរងគ្រោះចំនួន១០ឯកសារ ស្មើនឹង១.២១៩ទំព័រ។
- ចងក្រង និងសង្ខេបព័ត៌មានពីឯកសារចម្លើយសារភាពជនរងគ្រោះចំនួន ១៩៥ឯកសារ។
- ផ្ទៀងផ្ទាត់ឯកសារចម្លើយសារភាពជនរងគ្រោះពីក្រុមអ្នកស្រាវជ្រាវមកពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំនួន២៩៥ឯកសារ និងស្កេនឯកសារចំនួន១៦៧ទំព័រ។
- ចុះបញ្ជីសារពើភណ្ឌក្នុងឃ្លាំងបានចំនួន៨០វត្ថុ។

- សិស្សសាលា German Cambodain Conservation School (GCCS)ចំនួនពីរនាក់បានមករៀនជួសជុលលោហៈ នៅរោងជាងជួសជុលសារមន្ទីរទួលស្លែង។
- បានទទួលភ្ញៀវជាតិ-អន្តរជាតិ ព្រះសង្ឃ សិស្ស និស្សិតចូលទស្សនាមានចំនួន**៩៧.៩៧០នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន**៩២.១៩២នាក់។**

__គ.មណ្ឌលវត្តភ្នំ៖__

- បានទទួលភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចូលទស្សនាមានចំនួន**២.១០៩០នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន **១៩.៤៩០នាក់**។

__ឃ.មណ្ឌលជើងឯក៖__

- បានទទួលភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចូលទស្សនាសរុបមានចំនួន**២៥.៧៧៧នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន**២១.២៨៦នាក់** ។

__*នាយកដ្ឋានបុរាណវត្ថុ៖*__

- បានបន្តបញ្ចូលទិន្នន័យវត្ថុបុរាណនៅខេត្តសៀមរាបទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ( Database)។
- បានរៀបចំរូបភាព និងខ្លឹមសារនៃបទបញ្ញត្តិដើម្បីធ្វើបដាផ្សព្វផ្សាយដាក់តាមកន្លែងសំខាន់ៗ។
- បានចុះសិក្សាស្វែងយល់បុរាណវត្ថុអំពីថ្ម នៅសារមន្ទីរជាតិ។
- បានផ្តល់សេវាពិនិត្យវត្ថុសិល្បៈនាំចូល-នាំចេញបានចំនួនសរុប**៣៩៨រូប** ទទួលបានថវិកាចំនួន **៥.៥២៣.០០០រៀល** បង់ចូលថវិការដ្ឋ។

__*នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា៖*__

- បានចុះទៅធ្វើការអភិរក្ស សិក្សាវិភាគ និងធ្វើបញ្ជីសារពើភណ្ឌកុលាលភាជន៍ ដែលបានមកពីស្ថានីយសំពៅលិចក្រោមទឹក នៅកោះស្ដេច ខេត្តកោះកុង។
- បានសហការធ្វើកំណាយស្រាវជ្រាវបន្តជាមួយសាកលវិទ្យាល័យអ៊ីលីណយ សហរដ្ឋអាមេរិក នៅតំបន់បាកាន (ប្រាសាទព្រះខ័នកំពង់ស្វាយ) ខេត្តព្រះវិហារ។
- បានអមដំណើរឯកឧត្តមអគ្គនាយកបេតិកភណ្ឌ ចុះទៅផ្សព្វផ្សាយច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងកំណត់និយាមការដើម្បីបោះបង្គោលដែនការពារតំបន់ស្ថានីយបុរាណនៅស្រះសារពើយុត្ត និងរាជធានីវាំងចាស់ នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

__*ការងារបេតិកភណ្ឌរូបីតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត៖*__

__*មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖*__

- បានបន្តរៀបចំថែរក្សាការពារសណ្ដាប់ធ្នាប់ សោភ័ណភាព អនាម័យមណ្ឌលវត្តភ្នំ បានល្អជាប្រចាំ។
- បានចុះត្រួតពិនិត្យការឈូសឆាយក្នុងបរិវេណទីទួលបុរាណនៅភូមិមូលជើងឯក ខណ្ឌដង្កោ។

__*មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្ដាល ៖*__

- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរស្រុកកៀនស្វាយ ចុះពិនិត្យ និងធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណក្នុងសារមន្ទីរស្រែអំពិលមានចំនួន១២៩ដុំផ្ទាំង។

- ឆ្នាំភ្នំព្រះរាជទ្រព្យ បានពង្រឹងការងារតាមគោលដៅទាំង៨ នៅលើខ្នងភ្នំ និងទីតាំងខាងក្រោមព្រះសក្យមុនីចេតីយ។
- ទទួលប្រាក់ពីព្រះគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ដែលបានឧបត្ថម្ភថ្លៃភ្លើងចំនួន១.១៦០.០០០រៀល សម្រាប់បំភ្លឺនៅព្រះសក្យមុនីចេតីយ និងឧបត្ថម្ភថវិកាដល់ឆ្នាំចំនួន២០.០០០រៀល។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖</u>***

- បានសហការជាមួយគណៈកម្មការវត្តបោសសម្អាត កាប់ឆ្ការព្រៃផ្លូវចូលរូង និងបរិវេណរមណីយដ្ឋានភ្នំសសៀរជាប្រចាំ។
- បានចុះពិនិត្យទូលអង្គ "អង្គដំណាក់" ទើបស្រាវជ្រាវឃើញថ្មី នៅសង្កាត់អូរក្រសារ ក្រុងកែប។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖</u>***

- បានបន្តចុះស្រង់ស្ថិតិប្រាសាទ ទួលប្រាសាទ គ្រឹះប្រាសាទ ស្ថានីយបុរេប្រវត្តិ និងរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖</u>***

- បានសហការជាមួយមន្ត្រីនគរបាលខេត្ត និងមន្ត្រីជំនាញសារមន្ទីរជាតិ ចុះធ្វើកោសល្យវិច្ច័យវត្ថុសិល្បៈចំនួន០៧រូប អំពីលោហៈដែលចាប់បានពីជនល្មើស។
- បានបណ្តុះបណ្តាលដល់សិស្សវិទ្យាល័យកំពង់ឈើទាល ផ្នែកស្រាវជ្រាវបុរាណវិទ្យារៀងរាល់ថ្ងៃសៅរ៍ និងអាទិត្យ។
- បានកាត់កូនស្មៅដែលដុះនៅលើប្រាសាទ N11, N7 និងប្រាសាទតោ។
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន២៨នាក់ (អន្តរជាតិចំនួន១១នាក់) ប្រាសាទសំបូរចំនួន៤.១៧៧នាក់ (អន្តរជាតិចំនួន១ .៤៨៧នាក់) រមណីយដ្ឋានភ្នំសន្ទុកចំនួន១ .១៨៦នាក់ (អន្តរជាតិចំនួន៨២នាក់) និងវត្តប្រាសាទចំនួន១៧នាក់ (អន្តរជាតិចំនួន០៧នាក់)។
- កិច្ចសហការជាមួយអង្គការ WASEDA ៖
    - បានសម្អាតស្មៅ និងយកល្បាស់នៅប្រាសាទ N1។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ ៖</u>***

- បានចុះពិនិត្យវត្ថុបុរាណនៅសារមន្ទីរនរៈបុរី។
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរនរៈបុរីសរុបចំនួន៥៩៧នាក់។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖</u>***

- បានសហការជាមួយគ្រប់ការិយាល័យវប្បធម៌ស្រុក-ក្រុងក្នុងការការពារ និងថែរក្សាបុរាណស្ថាន និងបុរាណវត្ថុដែលត្រូវបានរក្សាទុកដោយសហគមន៍មូលដ្ឋាន។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖</u>***

- បានថែរក្សាវត្ថុបុរាណដែលមាននៅក្នុងសារមន្ទីរខេត្ត និងសារមន្ទីរស្រុកអង្គរបុរី។
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន១០នាក់ និងសារមន្ទីរស្រុកអង្គរបុរីចំនួន១៧៥នាក់ (អន្តរជាតិចំនួន៣០នាក់)។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តត្បូងឃ្មុំ ៖</u>***

- បានចុះទៅទៅវាស់វែងទួលទុំទាវ ស្ថិតនៅស្រុកត្បូងឃ្មុំ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖</u>***

- បានចុះផ្សព្វផ្សាយទប់ស្កាត់សកម្មភាពបំផ្លាញស្ថានីយបុរាណនៅស្រុកអូរជ្រៅ។
- បានរៀបចំស្លាកសញ្ញាបង្ហាញផ្លូវចូលទៅប្រាសាទតាព្រហ្ម និងសារមន្ទីរបុរាណវិទ្យាទេពកោសា-ស្នាយ។
- បានរៀបចំដាក់បង្គោលភ្លើងនៅផ្លូវចូលប្រាសាទបន្ទាយឆ្មារ (ខាងកើត)។
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន១៧២នាក់ (ភ្ញៀវអន្តរជាតិ១៦នាក់) ចូលប្រាសាទបន្ទាយឆ្មារចំនួន៩១៨នាក់ (ភ្ញៀវអន្តរជាតិ១១៨នាក់) និងចូលសារមន្ទីរបុរាណវិទ្យាទេពកោសា-ស្នាយចំនួន១១នាក់ (ភ្ញៀវអន្តរជាតិ០១នាក់)។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖</u>***

- បានចុះទៅកំណត់ទួលបុរាណ "ទួលពោន ឬ ទួលពួន" នៅស្រុកមោងឫស្សី។
- បានទទួលវត្ថុសិល្បៈចំនួន០១រូប គឺ "រូបដំរីស្ពាន់"។
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន៥៩នាក់ (អន្តរជាតិចំនួន៣៨នាក់)។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖</u>***

- បានគូរគំនូរនៅអាស្រមលោកយាយទេព លោកយាយមៅ ដោយប្រើប្រាស់ថវិកាសប្បុរសជន។
- បានចុះពិនិត្យវត្ថុបុរាណនៅវត្តពោធិទង នៅស្រុកកញ្ជៀច។
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន១២នាក់។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖</u>***

- បានចុះទៅក្រុមហ៊ុន អេហ្វភី ម៉ាឡេស៊ី ដើម្បីធ្វើចំណាត់ថ្នាក់ដី និងវាស់វែង នៅស្រុកគូលែន។
- បានទទួលភ្ញៀវចូលទស្សនាប្រាសាទព្រះខ័ន្តធំចំនួន៨៩នាក់ (អន្តរជាតិចំនួន២៩នាក់) និងប្រាសាទក្រពុំឈូកចំនួន៨៨នាក់ (អន្តរជាតិចំនួន០៣នាក់)។
- សកម្មភាពឆ្នាំត្រួសត្រាយព្រៃសម្អាតតាមប្រាសាទបុរាណបានចំនួន៣៩.៧១០ម៉ែត្រការ៉េ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី ៖</u>***

- បានចុះពិនិត្យ និងធ្វើការសម្អាតព្រៃនៅប្រាសាទយ៉ាកណាំងនៅស្រុកអូរយ៉ាដាវ។
- បានចុះត្រួតពិនិត្យ និងដាក់ស្លាកសញ្ញាហាមឃាត់ការកាប់រានព្រៃឈើនៅតំបន់គ្រឹះប្រាសាទព្រះពុទ្ធ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖</u>***

- បានផ្សព្វផ្សាយសេចក្តីសម្រេចលេខ០១ស.រ ស្តីពីការកំណត់បរិវេណ ប្រាសាទ ទួល ស្រះត្រពាំង ស្ពានបុរាណ នៅក្រុងសៀមរាប ស្រុកជីក្រែង និងស្រុកអង្គរជុំ។
- បានចុះធ្វើការណែនាំដល់ប្រជាពលរដ្ឋចំនួន១គ្រួសារឲ្យបញ្ឈប់ការចាក់ដីលុបវាលភក់យកដីចំណីភ្នំរពំង នគរភា សស្ថិតនៅឃុំនគរភា សស្រុកអង្គរជុំ ។

- ទទួលឲ្យភ្ញៀវចូលទស្សនាសារមន្ទីរជាតិអង្គរសរុបមានចំនួន៨.២៣៩នាក់ (ភ្ញៀវអន្តរជាតិចំនួន ៧.៨៩៣នាក់) សារមន្ទីរព្រះនរោត្តមសីហនុចំនួន២.៣៧៥នាក់(ភ្ញៀវអន្តរជាតិចំនួន២.៣១៥នាក់) សារមន្ទីរវត្តរាជបូព៌ចំនួន៥៨៣នាក់ (ភ្ញៀវអន្តរជាតិចំនួន៤៦១នាក់) និងមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំនួន៩.៨៦០នាក់ (ភ្ញៀវអន្តរជាតិចំនួន៩.៤២៧នាក់)។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖</u>***

- បានចុះពិនិត្យមើលទីតាំងដែលប្រជាពលរដ្ឋសុំសាងសង់សំណង់រឹងមួយកន្លែងចំងាយប្រហែល ២០០ម៉ែត្រពីប៉ែកខាងលិចប្រាសាទព្រះគោ នៅជិតទួលអង្គខ្មៅ ឃើញថាពុំមានប៉ះពាល់ស្ថានីយបុរាណទេ។
- បានចុះត្រួតពិនិត្យការឈូសឆាយផ្លូវខាងលិចប្រាសាទព្រះគោ ឃើញថាពុំមានប៉ះពាល់ទួលប្រាសាទទេ។
- បានចុះធ្វើការណែនាំដល់លោកគ្រូនៅអនុវិទ្យាល័យថាឡាបរិវ៉ាត់ពីបញ្ហាការឈូសឆាយដីពីព្រោះ នៅស្រុកថាឡាបរិវ៉ាត់សំបូរទៅដោយស្ថានីយបុរាណជាច្រើន និងមុនពេលធ្វើការឈូសឆាយ ឬសង់សំណង់អ្វីមួយត្រូវរាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖</u>***

- បានចុះត្រួតពិនិត្យទួលបុរាណ និងប្រាសាទបុរាណចំនួន១២លើក។
- បានចុះស្រាវជ្រាវវត្ថុបុរាណ និងចងក្រងប្រវត្តិផ្សេងៗចំនួន០១អត្ថបទ។
- បានចុះសហការជាមួយអាជ្ញាធរដែនដីធ្វើប្លង់ទួលបុរាណចំនួន០៤ប្លង់។
- បានផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌចំនួន០១លើក។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖</u>***

- បានចុះពិនិត្យប្រាសាទត្រពាំងប្រាសាទ ដែលកំពុងប្រឈមនឹងការបាក់រលំ។
- បានចុះហាមឃាត់ប្រជាពលរដ្ឋដែលមានដីក្បែរប្រាសាទកប់គង កុំឲ្យកាប់ព្រៃទន្ទ្រានដីចូល ក្នុងបរិវេណប្រាសាទ។

### ១.៣.៣. អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ៖

***<u>នាយកដ្ឋានអភិវឌ្ឍវប្បធម៌ ៖</u>***

- បានរៀបចំតុបតែងលម្អ តាំងពិព័រណ៍រូបថត ហ្វ៊ុង បដា សម្រាប់សន្និបាតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៥ នៅសាលសន្និសីទចតុម្មុខ។
- បានបន្តរៀបចំសារមន្ទីរខ្លែងខ្មែរ ដើម្បីបើកជូនមហាជនចូលទស្សនា និងសិក្សាស្រាវជ្រាវ។

***<u>នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ៖</u>***

- ថតវីដេអូឯកសារពីសកម្មភាពថ្នាក់ដឹកនាំ និងការងារអង្គភាពចំណុះក្រសួង បាន១៣ចំណងជើង។
- បានកំពុងតម្លើងវីដេអូស្តីពីល្ខោនរឿង "ព្រះនាងទិព្វសង្វារ"។
- បានទទួល និងផ្តល់ការអនុញ្ញាតថតភាពយន្តឯកសារ និងទូរទស្សន៍បរទេសបាន២ចំណងជើង។
- បានផ្តល់អាជ្ញាប័ណ្ណថ្មីធ្វើអាជីវកម្មភាពយន្ត-វីដេអូបាន២ច្បាប់។
- បានចុះបញ្ជីសុំផលិតវីដេអូខារ៉ាអូខេខ្មែរបាន៥លេខ វីដេអូរឿងខ្មែរបាន២ចំណងជើង។

- បានអនុញ្ញាតច្បាប់ថតវីដេអូរឿងខ្មែរ (០១ដុំចប់) បាន១ចំណងជើង។
- បានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូខារ៉ាអូខេខ្មែរបាន៩លេខ វីដេអូខ្មែរ(០១ដុំចប់)បាន ២ចំណងជើង។
- បានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូរឿងបរទេស (ភាយ) បាន១៣ ចំណងជើង និងចុះបញ្ជីកាសែតនាំចូលពីបរទេសបាន៤៣ចំណងជើង។
- បានទទួលចំណូលពីការផ្តល់សេវាកម្មភាពយន្ត-វីដេអូ សរុបចំនួន**៧.៩០៥.០០០រៀល** បង់ចូលថវិការដ្ឋ ។

## ***<u>នាយកដ្ឋានសិល្បៈទស្សនីយភាព៖</u>***

- បានប្រគំតន្ត្រី និងសម្តែងសិល្បៈទាំងមហាជន និងអាជីព សរុបចំនួន២៣៣លើក ក្នុងនោះនាយកដ្ឋានសិល្បៈសម្តែងក្នុងស្រុកបាន១១លើក។
- ក្រុមសិល្បៈបន្តហាត់សម និងតម្លើងស្នាដៃសិល្បៈសម្រាប់សម្តែងក្នុងស្រុក និងក្រៅប្រទេស។
- លោកគ្រូ អ្នកគ្រូនៃនាយកដ្ឋានសិល្បៈទស្សនីយភាព បានចុះបង្ហាត់ដល់សិល្បករ សិល្បការិនីតាមមូលដ្ឋានដើម្បីត្រៀមចូលរួមក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស។

## ***<u>នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ៖</u>***

- បានជ្រើសរើសប្រធានបទសម្រាប់មហោស្រពសិល្បៈជាតិឆ្នាំ២០១៦ គំនូរបុរាណស្តីពី "ហនុមានចែចង់នាងសុវណ្ណមច្ឆា"។
- បានចូលរួមរៀបចំ Logo (គំនូរព្រាង) សម្រាប់មហោស្រពយុវជនកម្ពុជា ។
- បានចូលរួមរៀបចំគំនូរព្រាងក្បាច់ផ្កាសម្រាប់តុបតែងលម្អក្នុងពិធីអង្គរសង្ក្រាន្តឆ្នាំ២០១៦។
- បានរៀបចំរូបថតស្តីពីសម្ភារៈរបស់សិល្បករ គំនូរកសិកម្មសម្រាប់ចូលរួមតាំងពិព័រណ៍អាស៊ាននៅប្រទេសមីយ៉ាន់ម៉ា។

## ***<u>នាយកដ្ឋានសៀវភៅ និងការអាន ៖</u>***

***បណ្ណាល័យជាតិ៖**

- បានទទួលភ្ញៀវជាតិ-អន្តរជាតិចូលអានមានចំនួន ៥០៩នាក់។
- បានទទួលសៀវភៅពីស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាល (សៀវភៅគ្រប់ភាសា) ចំនួន ៣៣៤ក្បាល។
- អ្នកសិក្សាស្រាវជ្រាវបានខ្ចីសៀវភៅយកទៅអានមានចំនួន៦៨ក្បាល។
- បានទទួលទិនានុប្បវត្តិបាន១៥២ច្បាប់ ទស្សនាវដ្តីផ្សេងៗនិងព្រឹត្តិប័ត្របរទេសចំនួន២១៥ក្បាល។
- បានចែកលេខ ISBN ដល់អ្នកបោះពុម្ពចំនួន៣៥លេខ។
- បានដាក់ក្របសៀវភៅចាស់បាន២០ក្បាល ស្កេនសៀវភៅបាន០៤ក្បាល និងតម្កល់សៀវភៅនិងទស្សនាវដ្តីបាន០៩ចំណងជើង។
- ធ្វើកាតាឡុកសៀវភៅគ្រប់ប្រភេទ និងទស្សនាវដ្តីជាភាសាខ្មែរ-បរទេសបាន២១៩ក្បាល។

## ***<u>ការងារបេតកភណ្ឌអរូបីតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖</u>***

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖</u>***

- បានបើកវគ្គបណ្តុះបណ្តាលស្តីពី "របៀបចងក្បិន និងស្លៀកសំឡុយក្នុងពិធីអាពាហ៍ពិពាហ៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
- បានរៀបចំប្រឡងមហោស្រពសិល្បៈយុវជនលើកទី២ ថ្នាក់រាជធានីភ្នំពេញ ក្រោមប្រធានបទ "វប្បធម៌ និងការអប់រំ យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព ឯកឧត្តម ប៊ុន សេរី អភិបាលរងរាជធានីភ្នំពេញ។
- បានត្រួតពិនិត្យកន្លែងលក់កាហ្វេបញ្ចាំងវីដេអូបាន៤៧ទីតាំង អាជីវកម្មអ៊ិនធើណេតបាន៦ទីតាំង ម៉ាស្សា-កោសជប់បាន៥ទីតាំង សម្អាងការបាន៦ទីតាំង ទីតាំងជួល -លក់ឌីសបាន៣៥ទីតាំង រោងភាពយន្តបាន២ទីតាំង។
- បានសហការជាមួយគណៈកម្មការចម្រុះខណ្ឌចុះចាប់ហ្គេមបាញ់ត្រី០១កន្លែង ដោយដកហូតបានទូហ្គេមបាញ់ត្រីចំនួន០១គ្រឿង និងសម្ភារៈមួយចំនួន។
- បានចុះកាត់ស្លាកស្លាកសញ្ញាដែលលើកតាំងខុសច្បាប់ចំនួន២១ផ្ទាំង។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ៖</u>***

- បានចុះបង្ហាត់ល្ខោននិយាយរឿង "លះបង់" របស់សិស្សវិទ្យាល័យ ហ៊ុន សែន សេរីភាព និងសហការជាមួយអ្នកគ្រូ សុភីលីន បង្ហាត់របាំក្បាច់បុរាណ "បណ្តាំព្រះម៉ែអប្សរា"ដល់សិស្សវិទ្យាល័យ ហ៊ុន សែន តាខ្មៅ ដើម្បីចូលរួមមហោស្រពយុវជនត្រៀមថ្នាក់ខេត្ត និងមហោស្រពយុវជនថ្នាក់ជាតិ លើកទី២ ឆ្នាំ២០១៦។
- បានសហការជាមួយនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម មន្ទីរទេសចរណ៍ខេត្ត និងអាជ្ញាធរមូលដ្ឋាន បើកវគ្គបណ្តុះបណ្តាលក្បាច់ចម្លាក់ខ្មែរ ដល់សិប្បករចំនួន៥០នាក់ នៅស្រុកពញាឮ។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖</u>***

- បានចុះហ្វឹកហាត់ល្ខោនអប់រំ០១ចំណាងជើង នៅវិទ្យាល័យ ហ៊ុន សែន ចំការដូង ដើម្បី ត្រៀមចូលរួមមហោស្រពសិល្បៈយុវជនទូទាំងប្រទេសលើកទី២ អបអរទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៨ ឆ្នាំ២០១៦។
- បានចុះត្រួតពិនិត្យ និងស្រង់ទិន្នន័យនៅស្ថានីយទូរទស្សន៍ខ្សែកាបក្រុងកែប។
- បានចុះពិនិត្យសិប្បកម្មធ្វើគ្រឿងសង្ហារិម០១កន្លែង នៅសង្កាត់កែប។
- បានសហការរៀបពិធីបង្ហើរខ្លែងខ្មែរ ដើម្បីអបអរសាទរ បុណ្យចូលឆ្នាំសកល ឆ្នាំ២០១៦ និងទិវាបុណ្យជាតិ ៧មករា ឆ្នាំ២០១៦ ដែលមានខ្លែងចូលរួមសរុបចំនួន២៣៦ ខ្លែង ក្នុងនោះខ្លែងឯកចំនួន៤២ខ្លែង និងខ្លែងច្នៃប្រឌិតចំនួន១៩៤ខ្លែង។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖</u>***

- បានបន្តចុះត្រួតពិនិត្យ និងស្រង់ស្ថិតិសិល្បៈទស្សនីយភាព សិល្បៈសូនរូប សិល្បៈភាពយន្ត និងអភិវឌ្ឍវប្បធម៌។
- ការិយាល័យច្រកចេញចូលតែមួយ បានទទួលពាក្យសុំច្បាប់ធ្វើអាជីវកម្មសរុបចំនួន៣៥ច្បាប់។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖</u>***

- បានបង្ហាត់សិល្បៈដល់សិស្សថ្នាលរៀងរាល់ថ្ងៃអាទិត្យ។
- បានតម្លើងបទភ្លេងរបាំ "សាឡុងជាន់ដែកតាឡែកកំពង់ធំ"។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ ៖*

- បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បើកមហោស្រពសិល្បៈយុវជនឆ្នាំទី២ថ្នាក់មូលដ្ឋានខេត្តឆ្នាំ២០១៦ និងបំផុលចលនាតាមវិទ្យាល័យក្នុងខេត្ត បង្កើតក្រុមសិល្បៈយុវជនតាមវិទ្យាល័យដើម្បីចូលរួមប្រកួតប្រជែងក្នុងមហោស្រពសិល្បៈយុវជនថ្នាក់មូលដ្ឋានខេត្តឆ្នាំ២០១៦។
- បានបន្តហ្វឹកហាត់សិល្បៈដល់សិស្សបន្តវេនរៀងរាល់ថ្ងៃសៅរ៍ និងអាទិត្យ។
- បានចុះពិនិត្យកែតម្រូវក្បូនខ្នាតចម្លាក់ខ្មែរនៅក្រុងច្បារមន។
- ការិយាល័យច្រកចេញចូលតែមួយក្រុងច្បារមន បានអនុញ្ញាតច្បាប់ប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន១៣ច្បាប់។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖*

- បានចុះត្រួតពិនិត្យកន្លែងលក់-ជួលឌីសក្នុងផ្សារសាមគ្គី សង្កាត់កំពង់បាយ ក្រុងកំពត។
- បានសម្របសម្រួលសំណើសុំថតខ្សែភាពយន្តរបស់ក្រុមហ៊ុន CTV ក្នុងក្រុងកំពត។
- បានចុះត្រួតពិនិត្យ និងណែនាំការដាក់តាំងផ្ទាំងយីហោ នៅសង្កាត់កំពង់បាយ និងសង្កាត់កំពង់កណ្តាល ក្រុងកំពត។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖*

- បានសហការរៀបចំការប្រឡងតែងកំណាព្យ សូត្រកំណាព្យ ពាន់រង្វាន់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ដោយមានបេក្ខជនចូលរួមប្រឡងអត្ថបទកំណាព្យចំនួន១៣៧អត្ថបទ និងសូត្រកំណាព្យចំនួន២៦នាក់។
- បានបញ្ជូនគ្រូសិល្បៈចំនួន០៤នាក់ ចុះទៅបង្រៀននៅវិទ្យាល័យសន្តប្រាង់ស្វរ នៅស្រុកត្រាំកក់។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តត្បូងឃ្មុំ ៖*

- បានចុះទៅពិនិត្យមើលសិប្បកម្មតម្បាញធ្វើអំពីឬស្សី នៅក្រុងសួង។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖*

- បានចុះផ្សព្វផ្សាយការទប់ស្កាត់ខ្សែភាពយន្តរឿង No Escape នៅទូទាំងខេត្ត។
- បានចុះត្រួតពិនិត្យវត្ថុសិល្បៈចម្លាក់ថ្មចំនួន០៨រូប ដែលនាំចេញទៅរាជធានីភ្នំពេញ។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖*

- បានចុះពិនិត្យការចាក់បញ្ចាំងវីដេអូតាមហាងកាហ្វេ និងចុះផ្សព្វផ្សាយដល់អាជីវករឲ្យមកធ្វើច្បាប់អាជីវកម្មបន្ត។
- បានចុះពិនិត្យនៅតាមកន្លែងសិប្បកម្មចម្លាក់ និងបន្តធ្វើច្បាប់អាជីវកម្ម។
- បណ្ណាល័យខេត្ត បានបើកទ្វារជូនសាធារណជនចូលអានសៀវភៅរៀងរាល់ថ្ងៃ លើកលែងថ្ងៃឈប់សម្រាក។
- បានចុះស្រង់ទិន្នន័យស្លាកយីហោនៅក្នុងតំបន់អភិរក្សខេត្តបាត់ដំបង។

- បានចុះជម្រុញអាជីវករឲ្យមកធ្វើច្បាប់បន្តនៅស្រុកបរវេល។
- ការិយាល័យច្រកចេញចូលតែមួយក្រុងបាត់ដំបង បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន១១ច្បាប់ និងនៅស្រុកបរវេល បានចំនួន០៣ច្បាប់។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖</u>***

- បានចុះពិនិត្យក្រុមសិល្បៈយុវជនវិទ្យាល័យបាភ្នំ។
- បានចុះពិនិត្យអាជីវកម្មជួល-លក់ឌីសចំនួន០២កន្លែង និងណែនាំអាជីវករឲ្យជួល -លក់ឌីសណាដែលមានទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅស្រុកពាមរក៍។
- បានចុះពិនិត្យសិប្បកម្មតម្បាញ ហូលផាមួង នៅស្រុកពោធិ៍រៀង។
- បានចុះពិនិត្យការដាក់តាំងស្លាកយីហោគ្រប់ប្រភេទនៅស្រុកកំពង់ត្របែក។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖</u>***

- បានចុះស្រង់ស្ថិតិសិល្បៈសូនរូប និងសិប្បកម្មនៅស្រុកឆែប។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ ៖</u>***

- បានតម្លើងស្នាដៃរបាំ "ដួងប្រេង" ដើម្បីចូលរួមមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំ២០១៦។
- បានចុះបង្ហាត់បង្រៀនរបាំ "ដួងប្រេង" ដល់សិស្សនៃសាលាសុវណ្ណភូមិ។
- បានចុះស្រង់ស្ថិតិ និងផ្សព្វផ្សាយសេចក្ដីជូនដំណឹងលេខ៣៥៤ វវ .ខសន របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ ដល់អាជីវករជួល-លក់ឌីសបានចំនួន១១កន្លែង។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគីរី ៖</u>***

- បានបង្ហាត់បង្រៀនបទភ្លេងពិណពាទ្យដល់ប្រជាពលរដ្ឋ០១ក្រុមជាប្រចាំ។
- បានបន្តយកសេចក្ដីជូនដំណឹងលេខ១២៧ ស.ជ.ណា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការហាមផ្សព្វផ្សាយ ជួល-លក់ ខ្សែភាពយន្តរឿង No Escape 2015 ដល់ក្រុមហ៊ុនទូរទស្សន៍ខ្សែកាប និងអាជីវករជួល-លក់ឌីសគ្រប់ស្រុកទាំងអស់ក្នុងខេត្ត។
- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ឌីសនៅក្រុងសែនមនោរម្យ។
- បានធ្វើខ្លែងឯកខ្មែរថ្មីបានចំនួន០១ និងបង្ហាត់បង្រៀនដល់យុវជនអំពីរបៀបធ្វើខ្លែងឯកខ្មែរ។
- បានចុះពិនិត្យ និងថែរក្សាអាស្រមទាំងបីនៅលើ មជ្ឈមណ្ឌលវប្បធម៌ជនជាតិនៅភ្នំដោះក្រមុំសម្រាប់ភ្ញៀវទេសចរណ៍មកលេងកំសាន្ត។
- ការិយាល័យច្រកចេញចូលតែមួយក្រុងសែនមនោរម្យ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន០២ច្បាប់។

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី ៖</u>***

- បានចុះត្រួតពិនិត្យការហ្វឹកហាត់របស់ក្រុមសិល្បៈមហាជនភូមិតងណងឡិៈរៀងរាល់សប្ដាហ៍។
- បានបង្ហាត់របាំជូនពរ និងរបាំគោះត្រឡោកដល់សិស្សរៀងរាល់ម៉ោងធ្វើការ។
- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ឌីសខុសច្បាប់នៅក្រុងបានលុង និងដកហូតបានឌីសចំនួន៦០៨បន្ទះ។

- បានចុះត្រួតពិនិត្យកន្លែងចាក់បញ្ចាំងទូរទស្សន៍ខ្សែកាប និងការចាក់បញ្ចាំងតាមហាងកាហ្វេនៅក្រុងបានលុង។
- បានចុះស្រង់ស្ថិតិហាងលក់វត្ថុអនុស្សាវរីយ៍ចំនួន១៨ទីតាំង នៅក្រុងបានលុង។
- បានចុះត្រួតពិនិត្យសិប្បកម្មតម្បាញរបស់បងប្អូនជនជាតិនៅសង្កាត់យក្សឡោម។

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖***

- បានផ្តល់លិខិតអនុញ្ញាតនាំចេញវត្ថុសិល្បៈទៅក្រៅប្រទេសចំនួន០៧រូប។
- ក្រុមសិល្បៈរបាំ និងសិល្បៈមហាជនចំនួន២៦ក្រុមបានសម្តែងតាមរោងមហោស្រព សណ្ឋាគារ ភោជនីយដ្ឋាន និងផ្សាររាត្រីជូនភ្ញៀវជាតិ និងអន្តរជាតិទស្សនាជាប្រចាំ។
- បានតម្លើងរបាំប្រពៃណីថ្មីបានចំនួន០៦របាំគឺ "របាំដំបែ", "របាំត្បាល់ក្តឿង", "របាំជូនពរ", "របាំផ្លិត" "របាំអប្សរា" , "របាំមនោសញ្ចេតនា"។
- បានចុះណែនាំ និងត្រួតពិនិត្យបទល្មើសភាពយន្ត -វីដេអូដល់អាជីវករភាពយន្ត-វីដេអូ (ការផលិត ការចាក់បញ្ចាំង ការជួល -លក់ឌីសអាសអាភាស និងគ្មានទិដ្ឋាការ) ឱ្យចូលរួមអនុវត្តតាមលិខិតបទដ្ឋានច្បាប់ចំនួន០៨កន្លែង នៅស្រុកក្រឡាញ់ ស្រុកពួក និងស្រុកប្រាសាទបាគង។
- បានចុះបង្រៀនចំណេះដឹងវប្បធម៌ដល់ស្រទាប់យុវវ័យ និងមហាជន នៅឃុំរុនតាឯក។
- បានចុះត្រួតពិនិត្យ និងណែនាំ ពន្យល់អំពីការអនុវត្តច្បាប់របស់ជំនាញដល់អាជីវករ -សិប្បករ ដែលកំពុងបម្រើសេវាកម្មទាក់ទងនិងជំនាញសិល្បៈសូនរូបនិងសិល្បៈសិប្បកម្មក្រុងសៀមរាប ស្រុកប្រាសាទបាគង ស្រុកសីសំនិ ស្រុកបន្ទាយស្រី ។
- សហការជាមួយក្រុមការងារចម្រុះសាលាក្រុងសៀមរាប ចុះកាត់របាំងកាត់ទទឹងផ្លូវ ចំនួន២៦ផ្ទាំង និងកាត់ប៉ាណូចំនួន៥៥ផ្ទាំង នៅក្រុងសៀមរាប។
- ការិយាល័យច្រកចេញចូលតែមួយក្រុងសៀមរាប បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន១៧ច្បាប់។

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖***

- បានបង្កើតស្នាដៃថ្មីចំនួន២ស្នាដៃគឺ របាំ "ភោគផលម្ចាស់ផ្អែម" និងល្ខោននិយាយ "ខ្ញុំយល់ហើយ"។
- បានបង្ហាត់របាំ "ភោគផលម្ចាស់ផ្អែម" ដល់សិស្សវិទ្យាល័យព្រះរាជបូជនីយកិច្ច។
- បានចុះជម្រុញអាជីវករប្រកបអាជីវកម្មសេវាកម្មវប្បធម៌ឲ្យមកបំពេញបែបបទសម្រាប់ឆ្នាំ២០១៦ ចំនួន០៦កន្លែងនៅក្រុងស្ទឹងត្រែង។

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖***

- បានចុះបង្ហាត់របាំដល់អង្គការក្មួយខ្មែរនៅឃុំតាសួសចំនួន០១ក្រុម។
- បានចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ឌីសចំនួន០២លើក រកឃើញឌីសគ្មានទិដ្ឋាការចំនួន៣៥០បន្ទះ។

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖***

- បានហ្វឹកហាត់សិល្បៈដល់ក្រុមសិល្បៈសិស្សវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ។

- បានចុះពិនិត្យបញ្ចាំងភាពយន្ត-វីដេអូ ដែលគ្មានទិដ្ឋាការពីក្រសួងវប្បធម៌ និងបានធ្វើការណែនាំដល់អាជីវករជួលមេក្រូ ធុងបាស វីដេអូចល័ត អំពីកម្រិតសម្លេង នៅក្រុងសំរោង។
- បានចុះពិនិត្យសកម្មភាពសិប្បកម្មចម្លាក់ឈើ នៅក្រុងសំរោង។
- បានចុះណែនាំជាងគំនូរអំពីរចនាបថក្បាច់បុរាណខ្មែរនៅក្រុងសំរោង។
- បានចុះពិនិត្យអាជីវកម្មអ៊ុតសក់ សម្អាងការ និងលម្អក្រចក និងចុះពិនិត្យការតាំងស្លាកយីហោផ្សាយពាណិជ្ជកម្មនៅក្រុងសំរោង។

**១.៣.៤. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**

- បានបន្តអនុវត្តកម្មវិធីសិក្សាឆ្នាំសិក្សា២០១៥-២០១៦។
- បានបើកបាថកថាស្តីពី "ទិដ្ឋភាព៣ នៃលោកតាឃ្លាំងមឿងនៅខេត្តពោធិសាត់"។
- សាកលវិទ្យាល័យមានការអភិវឌ្ឍ និងដំណើរការបានយ៉ាងល្អប្រសើរ ដោយខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយអង្គការ ស្ថាប័នអន្តរជាតិ សាកលវិទ្យាល័យក្នុង និងក្រៅប្រទេស ពិសេសផ្តោតលើការផ្តល់អាហារូបករណ៍ដល់សាស្ត្រាចារ្យ និងនិស្សិតទៅបន្តការសិក្សានៅក្រៅប្រទេស។

លទ្ធផលសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងខែមករា ឆ្នាំ២០១៦នេះ ជារួមឃើញថាមានដំណើរការល្អ ដោយសារស្មារតីមោះមុត ពុះពារ និងការតាំងចិត្តខ្ពស់របស់ថ្នាក់ដឹកនាំ ព្រមជាមួយការចូលរួមចំណែកយ៉ាងសកម្មរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់។ ការខិតខំប្រឹងប្រែងនេះនឹងនាំឲ្យឈានទៅសម្រេចបាននូវផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១៦ ហើយដែលនឹងនាំឲ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ ក្នុងវិស័យវប្បធម៌ជាចុងក្រោយបង្អស់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

**រដ្ឋមន្ត្រី**

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ ទេសចរណ៍ ព្រឹទ្ធសភា

-គណៈកម្មការទី ៧ រដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី (នាយកដ្ឋានសរុប)

-ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

-ក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ទីស្តីការគណៈរដ្ឋមន្ត្រី)

-ឯកសារ-កាលប្បវត្តិ